
អធិដ្ឋានផ្ដាំ
ព្រះហឫទ័យមេត្តាករុណា

# របៀបអធិដ្ឋានផ្កាំ



ព្រះយេស៊ូទ្រង់សន្យាយ៉ាងពិសេស អំពីការសូត្រ ផ្គាំនៃ «ព្រះហឫទ័យនៃមេត្តាករុណា»ថា «ចូរ ជំរុញឲ្យវិញ្ញាណទាំងឡាយសូត្រផ្គាំនៃ ព្រះហឫទ័យមេត្តាករុណា ដែលយើងបាន បង្រៀនកូន!» *(1541)* ...អ្នកណាក៏ដោយ ដែល សូត្រផ្គាំនេះ នឹងទទួលព្រះហឫទ័យមេត្តាករុណា ដ៏ក្រៃលែងនៅពេលគេស្លាប់។ *(687)*... បើគេ សូត្រធម៌នេះ សម្រាប់អ្នកជិតផុតដង្ហើម នោះ យើងនឹងឈរនៅចន្លោះព្រះបិតា និងអ្នកដែល ហៀបនឹងស្លាប់នោះ។ យើងឈររបៀបអ្នក សង្គ្រោះ ដែលមានចិត្តមេត្តាករុណា មិនមែន ឈរជារបៀបចៅក្រមទេ។ *(1541)*... យើងចង់ ប្រទានព្រះហឫទ័យប្រណីសន្តោសដែលមិន អាចនឹកស្មានបាន ដល់វិញ្ញាណទាំងឡាយណា ដែលជឿទុកចិត្តលើហឫទ័យមេត្តាករុណារបស់ យើង។ *(687)*... តាមរយៈការសូត្រផ្គាំនេះ កូន នឹងទទួលបានអ្វីគ្រប់យ៉ាង ប្រសិនបើអ្វីដែល កូនសុំនោះ ស្របនឹងបំណងរបស់យើង» *(1731)*...

# ១.ធ្វើសញ្ញាឈើឆ្កាង

ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ អាម៉ែន

# ២. ធម៌ប្រារព្ធ (តាមជ្រើសរើស)

បពិត្រព្រះយេស៊ូជាអម្ចាស់ ទោះបីព្រះអង្គយាងចាកចេញទៅហើយក្ដី ក៏ប្រភពនៃជីវិតដែលមកពីព្រះអង្គ នៅតែផុសចេញទៅដល់វិញ្ញាណទាំងឡាយ ហើយមហាសមុទ្រនៃព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ក៏នៅតែបើកសម្រាប់ពិភពលោកទាំងមូលដដែល។

ឱព្រះអង្គដែលជាប្រភពទឹកនៃជីវិតអើយ! ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គមិនអាចវាស់ស្ទង់បានឡើយ។ សូមព្រះអង្គឱបក្រសោបពិភពលោកទាំងមូល និងឱបក្រសោបយើងខ្ញុំ ដោយអស់ពីព្រះហឫទ័យរបស់ព្រះអង្គផង។ (1319)

***ឱព្រះលោហិតនិងទឹក ដែលហូរចេញ
ពីព្រះហឫទ័យរបស់ព្រះយេស៊ូ ជាជ្រោះ
នៃធម៌មេត្តាករុណាដល់កូនទាំងឡាយ។
កូនសូមផ្ញើជីវិតលើព្រះអង្គ! (84)
(***សូត្របីដង)

## ៣. ធម៌ឱព្រះបិតា (១ដង)

ឱ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថាន
បរមសុខអើយ!

សូមសម្ដែងព្រះបារមី ឲ្យមនុស្សលោក
ស្គាល់ព្រះនាមព្រះអង្គ

សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់

សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ បាន
សម្រេចនៅលើផែនដី ដូចនៅស្ថានបរម
សុខដែរ។

សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។

សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។

សូមកុំបណ្តោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ តែសូមរំដោះយើងខ្ញុំឲ្យរួចពីមារកំណាច។

## ៤. ធម៌បពិត្រព្រះនាងម៉ារី (១ដង)

បពិត្រព្រះនាងម៉ារី! ជាទីគាប់ព្រះហឫ-ទ័យព្រះជាម្ចាស់។ សូមព្រះនាងមានអំណរសប្បាយ ព្រះអង្គគង់នៅជាមួយនាង។ ព្រះអង្គបានប្រទានពរ ដល់នាងលើសស្ត្រីទាំងឡាយ ហើយទ្រង់ក៏ប្រទានពរដល់ព្រះយេស៊ូ ជាបុត្រនៃនាងដែរ។

ឱ! សន្តីម៉ារី ជាមាតាព្រះជាម្ចាស់!
សូមជួយអង្វរព្រះអង្គ ឲ្យយើងខ្ញុំជាអ្នកបាប នៅពេលឥឡូវនេះ ហើយនៅពេលស្លាប់ផង។ អាម៉ែន។

## ៥. ធម៌ជឿរបស់ក្រុមគ្រីស្តទូត

ខ្ញុំជឿលើព្រះជាម្ចាស់ ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ ជាព្រះបង្កើតមេឃ និងដី។ ខ្ញុំជឿលើព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយជាអម្ចាស់យើងខ្ញុំ។

*(អង្គប្រជុំឱនក្បាលបន្តិចរហូតដល់"ព្រះនាងព្រហ្មចារិនីម៉ារី")*

ព្រះអង្គមានកំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី។ ព្រះអង្គត្រូវគេឆ្កាង សោយទិវង្គត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះក្នុងរូងថ្មមួយ

ព្រះអង្គបានយាងចុះទៅស្ថានក្រោម លុះដល់ថ្ងៃទីបី ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ពីចំណោមមនុស្សស្លាប់។

ព្រះអង្គបានយាងឡើងស្ថានបរមសុខ ទៅគង់ខាងស្ដាំព្រះជាម្ចាស់ជាព្រះបិតា ដ៏មានឫទ្ធានុភាពសព្វប្រការ។

ព្រះអង្គនឹងយាងមកវិញ ដើម្បីវិនិច្ឆ័យមនុស្សទាំងរស់ទាំងស្លាប់។

ខ្ញុំជឿលើព្រះវិញ្ញាណដ៏វិសុទ្ធ

ខ្ញុំជឿព្រះសហគមន៍កាតូលិកដ៏វិសុទ្ធ និងសហភាពរវាងជនដ៏វិសុទ្ធទាំងឡាយ។

ខ្ញុំជឿថា មានការលើកលែងទោសមនុស្សឲ្យរួចពីបាប ហើយរូបកាយមនុស្សនឹងរស់ឡើងវិញ ព្រមទាំងមានជីវិតរស់នៅអស់កល្បជានិច្ចផង។ អាម៉ែន។

# ៦. ធម៌ «ឱព្រះបិតាដែលគង់នៅអស់កល្បជានិច្ច»

ឱព្រះបិតាដែលគង់នៅអស់កល្បជានិច្ច! កូនសូមថ្វាយទៅព្រះអង្គនូវព្រះកាយ ព្រះលោហិត ព្រះវិញ្ញាណ និងទេវភាពរបស់ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ គឺព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ ដើម្បីលុបលាងបាបរបស់យើងខ្ញុំ និងបាបរបស់ពិភពលោកទាំងមូល។

# ៧. សូត្រផ្គាំតូច១វគ្គ (១០គ្រាប់)

ដោយទុក្ខលំបាកដ៏សែនវេទនារបស់ព្រះយេស៊ូ សូមព្រះអង្គមេត្តាអាណិតអាសូរយើងខ្ញុំ និងពិភពលោកទាំងមូល។

( ១ជង់ =១គ្រាប់ផ្គាំតូច )



៨. សូត្រសារឡើងវិញ ពីលេខ ៦ និងលេខ៧មួយជុំទៀត។ ធ្វើយ៉ាងនេះរហូតដល់អស់។

## ៩. បញ្ចប់ដោយសូត្រធម៌ «ឱព្រះជាម្ចាស់ដ៏វិសុទ្ធ» (៣ដង)

ឱព្រះជាម្ចាស់ដ៏វិសុទ្ធ ប្រកបដោយឫទ្ធានុភាព និងមានព្រះជន្មគង់នៅអស់កល្បជានិច្ច។ សូមមេត្តាអាណិតអាសូរយើងខ្ញុំ និងពិភពលោកទាំងមូល។

## ១០. ធម៌សរុប (តាមជ្រើសរើស)

ឱព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅអស់កល្បជានិច្ច! ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាគ្មានទីបញ្ចប់។ ព្រះអង្គជាព្រភពនៃសេចក្ដីអាណិតអាសូរ ដែលមិនរីងស្ងួត។

ព្រះអង្គទតមកយើងខ្ញុំដោយព្រះហឫទ័យសប្បុរស ហើយព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គចម្រើនក្នុងយើងខ្ញុំ។ ពេលជួបទុក្ខលំបាក យើងខ្ញុំមិនដែលខកចិត្ត ឬអស់សង្ឃឹមឡើយ គឺព្រះអង្គប្រោសឲ្យយើងខ្ញុំមានជំនឿដ៏អស្ចារ្យ និងឲ្យយើងខ្ញុំភ្ជាប់ខ្លួនជាមួយព្រះអង្គដ៏វិសុទ្ធ ដែលមានព្រះហឫទ័យស្រឡាញ់និងមេត្តាករុណា។

## អធិដ្ឋានម៉ោង៣រសៀល ចំពោះ «ព្រះហឫទ័យមេត្តាករុណា»

ព្រះយេស៊ូបំភ្លឺសន្ដីហ្វូស្ទីណា យ៉ាងនេះថា «នៅម៉ោងបីរសៀល ចូរទូលអង្វរសូមសេចក្ដីមេត្តាករុណាររបស់យើង ជាពិសេសទូលអង្វរសម្រាប់អ្នកបាបទាំងឡាយ។ ពេលនេះ គឺជាពេលវេលានៃព្រះហឫទ័យមេត្តាករុណាដ៏ក្រៃលែង។ ក្នុងម៉ោងនេះ យើងនឹងមិនបដិសេធអ្វី

ឡើយ ចំពោះវិញ្ញាណដែលទូលអង្វរយើង ក្នុងប្រសិទ្ធភាពនៃការរងទុក្ខលំបាករបស់យើង»។ (១៣២០)...

បពិត្រព្រះយេស៊ូជាម្ចាស់ ទោះបីព្រះអង្គយាងចាកចេញទៅហើយក្ដី ក៏ប្រភពនៃជីវិតដែលមកពីព្រះអង្គ នៅតែផុសចេញទៅដល់វិញ្ញាណទាំងឡាយ ហើយមហាសមុទ្រនៃព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ក៏នៅតែបើកសម្រាប់ពិភពលោកទាំងមូលដដែល។

ឱព្រះអង្គដែលជាប្រភពនៃជីវិតអើយ! ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គមិនអាចវាស់ស្ទង់បានឡើយ។ សូមព្រះអង្គឱបក្រសោបពិភពលោកទាំងមូល និងឱបក្រសោបយើងខ្ញុំ ដោយអស់ពីព្រះហឫទ័យរបស់ព្រះអង្គផង។ (១៣១៩)

ឱព្រះលោហិតនិងទឹក! ដែលហូរចេញពីព្រះហឫទ័យរបស់ព្រះយេស៊ូ ជាជ្រោះនៃមេត្តាករុណាដល់កូនទាំងឡាយ។ កូនសូមផ្ញើជីវិតលើព្រះអង្គ!

**ឱព្រះជាម្ចាស់ដ៏វិសុទ្ធ! ប្រកបដោយឫទ្ធានុភាព និងមានព្រះជន្មគង់នៅ អស់កល្បជានិច្ច។ សូមមេត្តាអាណិតអាសូរយើងខ្ញុំ និងពិភពលោកទាំងមូល។**
*( សូត្រ៣ដង )*

បពិត្រព្រះយេស៊ូ ជាស្ដេចនៃធម៌មេត្តាករុណា កូនសូមផ្ញើជីវិតលើព្រះអង្គហើយ។ អាម៉ែន!



*អនុញ្ញាតចេញផ្សាយដោយ*
*លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ*